ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង Working Together for Positive Change

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា

The NGO Forum on Cambodia

លេខៈ ១៦៣....../NGOF/២០១៧/EP

**សូមគោរពជូន**

**ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រី នៃក្រសួងបរិស្ថាន**

**<u>កម្មវត្ថុ:</u> គោរពស្នើជូនមតិយោបល់របស់អង្គការសង្គមស៊ីវិល និងសហគមន៍ លើសេចក្តីព្រាង៩.១ «ក្រមធនធានធម្មជាតិ និងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា»** ដែលបានរៀបចំឡើងក្នុង សិក្ខាសាលាពិគ្រោះយោបល់របស់អង្គការសង្គមស៊ីវិលលើ «ក្រមធនធានធម្មជាតិ និងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា» នៅ ភោជនីយដ្ឋានទន្លេបាសាក់២ នា ថ្ងៃទី ២៧-២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧។

តបតាមកម្មវត្ថុខាងលើ តាងនាមឲ្យបណ្តាញអង្គការសង្គមស៊ីវិល និងក្រុមអ្នកបច្ចេកទេសច្បាប់ តំណាងសហគមន៍ ព្រមទាំងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា យើងខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តម ក៏ដូចជាសហការី ដែលបានយកចិត្តទុកដាក់ និងផ្តល់តំលៃចំពោះការចូលរួមយោបល់ពីអង្គការសង្គមស៊ីវិល និងសហគមន៍ ជាពិសេសលើដំណើរពិគ្រោះយោបល់លើសេចក្តីព្រាងនៃ «ក្រមធនធានធម្មជាតិ និងបរិស្ថាន» នេះ។

ការរៀបចំ *មតិយោបល់របស់អង្គការសង្គមស៊ីវិល និងសហគមន៍ លើសេចក្តីព្រាង «ក្រមធនធានធម្មជាតិ និងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា»* នេះ ជាការរួមចំណែកមួយដើម្បីធ្វើឲ្យក្រមនេះកាន់តែមានភាពប្រសើរឡើង និងដើម្បីផ្តល់ភាពងាយស្រួលដល់គ្រប់ស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងអង្គការសង្គមស៊ីវិលដែលអនុវត្តការងារទាក់ទងនឹងបរិស្ថានឲ្យកាន់តែយល់ដឹងពីច្បាប់បរិស្ថាន និងអាចចូលរួមពង្រឹងការអនុវត្តច្បាប់ទាំងនេះឲ្យកាន់តែមានប្រសិទ្ធិភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងន័យធ្វើការរួមគ្នាលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព និងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

អាស្រ័យដូចនេះ យើងខ្ញុំសូមភ្ជាប់ជូនជាមួយនូវ *មតិយោបល់របស់អង្គការសង្គមស៊ីវិល និងសហគមន៍ លើសេចក្តីព្រាង៩.១ «ក្រមធនធានធម្មជាតិ និងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា»*នេះ។ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលយកនូវមតិយោបល់ទាំងនេះដើម្បីបំពេញបន្ថែម ដោយក្តីអនុគ្រោះ។

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ២០១៧

**តំណាងសង្គមស៊ីវិល និងជានាយកប្រតិបត្តិ**

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

**បណ្ឌិត តឹក វណ្ណារ៉ា**

សូមគោរពចំលងជូន
ឯកឧត្តម **យុត ចាន់ដារ៉ា** ប្រធានក្រុមការងារបច្ចេកទេស
ស្តីពី ក្រមធនធានធម្មជាតិ និងបរិស្ថាន នៃក្រសួងបរិស្ថាន

ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ ទួលទំពូង ១ ភ្នំពេញ ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ ៣ # 9-11, St 476, Toul Tompoung I, Phnom Penh, P.O. Box 2295 Phnom Penh-3
Tel: (855) 23 214 429 Fax: (855) 23 994 063 E-mail: ngoforum@ngoforum.org.kh Website: www.ngoforum.org.kh

លេខ: ១៦៧...../NGOF/២០១៧/EP

**គោរពជូន**

**លោកស្រីមេធាវី សៅ កញ្ញា ក្រុមមេធាវីវិស្ណុ**

**កម្មវត្ថុ:** *គោរពស្នើជូនមតិយោបល់របស់អង្គការសង្គមស៊ីវិល និងសហគមន៍ លើសេចក្តីព្រាង៩.១ «ក្រមធនធានធម្មជាតិ និងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា»* ដែលបានរៀបចំឡើងក្នុងសិក្ខាសាលាពិគ្រោះយោបល់របស់អង្គការសង្គមស៊ីវិលលើ «ក្រមធនធានធម្មជាតិ និងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា» នៅភោជនីយដ្ឋានទន្លេបាសាក់២ នាថ្ងៃទី ២៧-២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧។

តបតាមកម្មវត្ថុខាងលើ តាងនាមឲ្យបណ្តាញអង្គការសង្គមស៊ីវិល និងក្រុមអ្នកបច្ចេកទេសច្បាប់ តំណាងសហគមន៍ ព្រមទាំងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា យើងខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនលោកស្រី ក៏ដូចជាសហការី ដែលបានយកចិត្តទុកដាក់ និងផ្តល់តំលៃចំពោះការចូលរួមយោបល់ពីអង្គការសង្គមស៊ីវិល និងសហគមន៍ ជាពិសេសលើដំណើរពិគ្រោះយោបល់លើសេចក្តីព្រាងនៃ «ក្រមធនធានធម្មជាតិ និងបរិស្ថាន» នេះ។

ការរៀបចំ ***មតិយោបល់របស់អង្គការសង្គមស៊ីវិល និងសហគមន៍ លើសេចក្តីព្រាង «ក្រមធនធានធម្មជាតិ និងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា»*** នេះ ជាការរួមចំណែកមួយដើម្បីធ្វើឲ្យក្រមនេះកាន់តែមានភាពប្រសើរឡើង និងដើម្បីផ្តល់ភាពងាយស្រួលដល់គ្រប់ស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងអង្គការសង្គមស៊ីវិលដែលអនុវត្តការងារទាក់ទងនឹងបរិស្ថានឲ្យកាន់តែយល់ដឹងពីច្បាប់បរិស្ថាន និងអាចចូលរួមពង្រឹងការអនុវត្តច្បាប់ទាំងនេះឲ្យកាន់តែមានប្រសិទ្ធិភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងន័យធ្វើការរួមគ្នាលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព និងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

អាស្រ័យដូចនេះ យើងខ្ញុំសូមភ្ជាប់ជូនជាមួយនូវ ***មតិយោបល់របស់អង្គការសង្គមស៊ីវិល និងសហគមន៍ លើសេចក្តីព្រាង៩.១ «ក្រមធនធានធម្មជាតិ និងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា»***នេះ។ សូមលោកស្រី ទទួលយកនូវមតិយោបល់ទាំងនេះដើម្បីបំពេញបន្ថែម ដោយអនុគ្រោះ។

សូមលោកស្រី ទទួលនូវការគោរពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ២០១៧

**តំណាងសង្គមស៊ីវិល និងនាយកប្រតិបត្តិ**

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

NGO FORUM ON CAMBODIA

**បណ្ឌិត តឹក វណ្ណារ៉ា**



ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ ទួលទំពូង ១ ភ្នំពេញ ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ ៣ #9-11, St 476, Toul Tompoung I, Phnom Penh, P.O. Box 2295 Phnom Penh-3
Tel: (855) 23 214 429 Fax: (855) 23 994 063 E-mail: ngoforum@ngoforum.org.kh Website: www.ngoforum.org.kh

## មតិយោបល់របស់អង្គការសង្គមស៊ីវិល
## លើសេចក្តីព្រាង«ក្រមធនធានធម្មជាតិ និងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា»
## ***លើកំណែក្រម៩.១***

ក្នុងនាមសង្គមស៊ីវិល យើងខ្ញុំទាំងអស់គ្នា មានសេចក្តីរីករាយ និងសារទរជាខ្លាំង សម្រាប់វឌ្ឍនភាពនៃក្រម ដែលប្រកបដោយភាពពេញលេញ និងការចូលរួមដ៏ផុលផុសពីសាធារណៈជន និងអ្នកពាក់ព័ន្ធ។ វឌ្ឍនភាពនៃកំណែក្រម ៩.១ កាន់តែមានភាពល្អប្រសើរ ក៏ព្រោះតែភាពដឹកនាំនិងសុឆ្ន័ទៈដ៏ខ្ពង់ខ្ពស់របស់ថ្នាក់ដឹកនាំដោយ ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីនៃក្រសួងបរិស្ថាន និងការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពនៃក្រុមអ្នកច្បាប់វិស្ណុ។ ក្នុងនាមក្រុមសង្គមស៊ីវិល យើងខ្ញុំទាំងអស់គ្នា ក៏ព្យាយាមជួយឲ្យអស់លទ្ធភាព សំដៅជម្រុញឲ្យមានការឆ្លើយតបលើទិដ្ឋភាពជាក់ស្តែងលើបញ្ហាសង្គម បរិស្ថានកម្ពុជាយើង។ ដំណើរការពិនិត្យលើកំណែ ៩.១នេះ ក្រុមយើងបានធ្វើឡើង ៤ដំណាក់កាលធំ៖

១. ការពិនិត្យនិងផ្តល់យោបល់តាមវិស័យ/ផ្នែក ដោយអ្នកជំនាញការឯករាជ្យ។
២. ប្រជុំពិភាក្សាជាមួយសហគមន៍និងបណ្តាញសង្គមស៊ីវិល នៅថ្ងៃ២៧-២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយមានការចូលរួមសរុបប្រមាណ១០០នាក់។
៣. ការពិនិត្យផ្ទៀងផ្ទាត់ បូកសរុបនិងសំយោគពីអ្នកជំនាញជាន់ខ្ពស់ឯករាជ្យ។
៤. ក្រុមអង្គការសង្គមស៊ីវិល និងដៃគូរពិនិត្យ ថ្លឹងថ្លែង មុននឹងដាក់ជូនក្រុមអ្នកច្បាប់វិស្ណុ និងក្រសួងបរិស្ថាន។

យោងតាមដំណើរការខាងលើ យើងទទួលបានលទ្ធផលជាផ្លែផ្កា ដែលជាសំណូមពរចាំបាច់មួយចំនួនសម្រាប់ក្រុមប្រឹក្សាអ្នកច្បាប់វិស្ណុ និងក្រសួងបរិស្ថានពិចារណា និងបញ្ចូលនៅក្នុងក្រម។ ទាំងនេះជាសេចក្តីសង្ខេបរួមពីចំណុចដែល គួរពិចារណា ចំណែកយោបល់លំអិតតាមមាត្រានីមួយៗ និងមានភ្ជាប់ជូនឯកសារតាមផ្នែក/វិស័យ។ យោបល់ និងការស្នើកែសម្រួលសង្កត់ធ្ងន់លើ គោលការណ៍ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC) ការចូលរួមជាសាធារណៈ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការប្រែប្រួលអាកាសធាតុ តំបន់ការពារ និងសហគ្រប់គ្រង។

**១.** សំណូមពរ ពិនិត្យឡើងវិញឲ្យបានគ្រប់ជ្រុងជ្រោយសម្រាប់ក្រម នូវពាក្យ និងឃ្លាឃ្លោង ដើម្បីធានាសុក្រិតភាព និងសុគតិភាព។ ឧទាហរណ៍ពាក្យថា គណៈកម្មការ ឬគណៈកម្មាធិការ ដែលបានចែងក្នុងមាត្រា១៤៦ មាត្រា១៥៦ មាត្រា២៤០ មាត្រា២៨០ជាដើម និង ពាក្យគ្រប់គ្រងរួមគ្នា និងសហគ្រប់គ្រងក្នុងជំពូក៣ មាត្រា២៤៧ ៣៤៧ និង មាត្រា១១៣៨។ល។ ជាពិសេសសូមពិនិត្យកែសម្រួលឃ្លាឃ្លោង ល្បះឲ្យមានលក្ខណៈនិងបែបបទជាភាសាខ្មែរផ្លូវការ(វិធានច្បាប់) ជាជាងប្រើប្រាស់ទម្រង់ការសរសេរភាសាអង់គ្លេស ដោយពន្យល់ឬ បែបអសកម្មលើប្រធានបទ (ឧ.ហ. លើមាត្រា២៤

មាត្រា១០១ មាត្រា៣៣៦ មាត្រា៤២៨ ...)។ សទ្ទានុក្រម គួរតែភ្ជាប់មកជាមួយក្រមនេះ ព្រោះអត្ថន័យនៃវាក្យស័ព្ទមួយចំនួនមានន័យជ្រៅ និងលក្ខណៈបច្ចេកទេស។

២. ដោយយោងតាម៖ ការយល់ព្រមជាមុន ដោយសេរី បន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ សម្រាប់ជនជាតិដើមភាគតិច (FPIC), អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) និងអនុសញ្ញាអន្តរជាតិនានាដែលកម្ពុជា ជាប្រទេសហត្ថលេខី។ សូមកែសម្រួលពាក្យពេចន៍ ក្នុងមាត្រា៣០ ១២៥ ១២៦ និង១២៧។

- មាត្រា ១៨៖ គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ សម្រាប់សហគមន៍ជនជាតិដើមភាគតិចសកម្មភាព ឬ គម្រោងដែលស្នើសុំ ដែលអាចប៉ះពាល់ដល់ដីធ្លី ឬធនធានដទៃទៀត ជាពិសេស ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលនូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ របស់ជនជាតិដើមភាគតិច នៅគ្រប់ដំណាក់កាលនៃគម្រោងដែលស្នើរឡើង រួមមាន៖ ១២ ដំណាក់កាលសិក្សាស្រាវជ្រាវបឋម () ដំណាក់កាលរៀបចំគម្រោង និង ៣៤ និង ដំណាក់កាលអនុវត្តគម្រោង ()ដំណាក់កាលបញ្ចប់គម្រោង។

- មាត្រា២៦៖ ម្ចាស់គម្រោង ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ឱកាសឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព និងពេញលេញរបស់ជនជាតិដើមភាគតិច ដែលអាចទទួលរងផលប៉ះពាល់ដោយសេចក្តីសម្រេចទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ និងត្រូវតែទទួលបាននូវការយល់ព្រមដោយសេរី (លើសពី២ភាគ៣) និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ពួកគេ មុនពេលដែលសេចក្តីសម្រេចនោះត្រូវបានធ្វើឡើង ។ ជនជាតិដើមភាគតិច ដែលអាចរងផលប៉ះពាល់ពីគម្រោងស្នើសុំ មានសិទ្ធិពេញលេញក្នុងការចូលរួមនូវគ្រប់ដំណាក់កាលនៃគម្រោងដោយគ្មានការបង្ខិតបង្ខំ ឬគម្រាមកំហែង។ ការចូលរួមត្រូវតែផ្តល់ជូនឱ្យបានទាន់ពេលវេលា ហើយអ្នកចូលរួមត្រូវទទួលបានការជូនដំណឹងពេញលេញអំពីព័ត៌មានពាក់ព័ន្ធទាំងអស់ នៅក្នុងទម្រង់និងភាសាដែលសមរម្យ។

- មាត្រា២៧៖ ការយល់ព្រមជាមុន ដោយសេរី ក្រសួង ស្ថាប័នពាក់ព័ន្ធ មិនត្រូវឯកភាពលើផែនការ កម្មវិធី ឬ សំណើគម្រោង ដែលអាចប៉ះពាល់ដល់ជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ជនជាតិដើមភាគតិចបានឡើយ ។ ចំណែកផែនការ កម្មវិធី ឬគម្រោងដែលបាននិងកំពុងអនុវត្តហើយមានការប៉ះពាល់ដល់ជនជាតិដើមភាគតិច ត្រូវតែរៀបចំយន្តការពិគ្រោះពិភាក្សា និងដោះស្រាយឡើងវិញជាមួយពួកគាត់សំដៅទទួលបានព័ត៌មានមានពេញលេញ និងយល់ព្រមដោយសេរីពីការអភិវឌ្ឍទាំងនេះ។

- មាត្រា២៨៖ នីតិវិធីសម្រាប់ការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិចក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតឧបករណ៍គតិយុត្តសមស្របស្តីពីនីតិវិធីសម្រាប់ការពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈរបស់ជនជាតិដើមភាគតិច នៅក្នុងការសម្រេចចិត្ត ដែលពាក់ព័ន្ធដី និងសហគមន៍របស់ជនជាតិដើមភាគតិច ដើម្បីធានាបាននូវបុព្វសិទ្ធិពេញលេញរបស់ពួកគាត់។

**៣. ការចូលរួមជាសាធារណៈ** នៅតែជាចំណុចសំខាន់ និងចាំបាច់បំផុតសម្រាប់ការអភិរក្ស និងគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ជាពិសេសជាមួយសម្ពាធពីការប្រែប្រួលអាកាសធាតុ តម្រូវការវិនិយោគ និងការអភិវឌ្ឍ។ សំណូមពរកែសម្រួលពាក្យពេចន៍នៅមាត្រា (២) (៧) (២១) (២៦) (២៨) (៣០៥) (៣៤៦) (៥២៤) (៥២៧) (៥៣៨) (៨០៨)។ ចំណុចសំខាន់ដែលត្រូវបញ្ចូលគឺ៖

- មាត្រា ២៤ (ច)៖ រាល់គម្រោងអភិវឌ្ឍ និងផែនការវិនិយោគបាននិងកំពុងអនុវត្ត ដោយពុំមានការចូលរួមជាសាធារណៈ ឬមិនពេញលេញត្រូវតែរៀបចំផែនការ និងអនុវត្តន៍ការចូលរួមជាសារធារណៈឲ្យបានពេញលេញក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ចូលធរមាននៃក្រមនេះ ។
- មាត្រា៩៥(ង)៖ អនុម័តលិខិតបទដ្ឋានគតិយុត្តនានា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានយុទ្ធសាស្ត្រ ផែនការគ្រប់គ្រងបរិស្ថាន ផែនការនៃចូលរួមសាធារណៈដែលភ្ជាប់មកជាមួយ និងការកំណត់វិសាលភាព និងលក្ខខណ្ឌការងារនៃគម្រោងនីមួយៗ។ (ចំណុចនេះនៅលើឯកសារពី SEA/EIA)។
- មាត្រា១០៤ (ចំណុចចុងក្រោយ)៖ នៅពេលដែលគម្រោងស្នើសុំ តម្រូវឲ្យធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំសេចក្តីព្រាងលក្ខខណ្ឌការងារ ដោយអនុលោមតាមបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន រួចដាក់សុំការអនុម័តជាស្ថាពរ ពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ផ្អែកលើលក្ខខណ្ឌការងារដែលទទួលបានការឯកភាពដោយភ្ជាប់មកជាមួយផែនការចូលរួមជាសាធារណៈនៃដំណើរការគម្រោង។
- មាត្រា១២៤(ក)៖ បានទទួលដំណឹងទាន់ពេលវេលា គ្រប់ជ្រុងជ្រោយអំពីគម្រោង និងតាមដំណាក់កាលនីមួយៗនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- មាត្រា១២៩៖ (ត្រង់ចំណុចចុងក្រោយ) នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយត្រូវពិគ្រោះពិភាក្សាពេញលេញនិងស៊ីជំរៅ ជាមួយសាធារណជន ជនជាតិភាគតិច ជនងាយរងគ្រោះ ស្ត្រី និងអ្នកធ្លាប់ទទួលផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍។
- មាត្រា ១៣៣៖ បែបបទ និងនីតិវិធីនៃការដោះស្រាយបណ្តឹង ឬញត្តិនេះត្រូវកំណត់យោងតាមនីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានចែងក្នុងក្រមនេះ ដោយត្រូវពិគ្រោះពិភាក្សាពេញលេញ និងស៊ីជម្រៅ ជាមួយសាធារណជន ជនជាតិភាគតិច ជនងាយរងគ្រោះ ស្ត្រី និងអ្នកធ្លាប់ទទួលផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍។

៤. កែសម្រួលមាត្រាមួយចំនួន នៅមាតិកាទី២ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងជំពូកទី១ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ៖ មាត្រា៧៧ ៧៩ ៨៤ ៨៥ ៨៦ និងមាត្រា៨៧។ សំណូមពរកែសម្រួល និងបញ្ចូលចំណុចមួយចំនួនក្នុងមាត្រា៨១និង៨២ដូចខាងក្រោម។

- មាត្រា ៨១៖ នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ត្រូវដាក់បញ្ចូលនូវដំណាក់កាលដូចខាងក្រោម៖

១) ការកំណត់វិសាលភាពសំណើសុំ និងលក្ខខណ្ឌការងារសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត
២) ការរៀបចំសេចក្តីព្រាងរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ។
៣) ការចូលរួមជាសាធារណៈលើសេចក្តីព្រាងរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ។
៤) ការរៀបចំរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្តចុងក្រោយ ។
៥) សេចក្តីសម្រេចលើរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ។
៦) ការអនុវត្តរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្រ្តចំពោះសំណើ ។
៧) រៀបចំបង្កើត និងសម្របសម្រួលជាមួយស្ថាប័ន ឬក្រុមប្រឹក្សាឯករាជ្យសំដៅអនុវត្តការតាមដាន និងវាយតម្លៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន។

- មាត្រា ៨២៖ សមត្ថកិច្ចក្រសួង ស្ថាប័ន ដែលនឹងអនុវត្តនីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ត្រូវតែជាក្រសួង ស្ថាប័ន អន្តរវិស័យ ឬតាមវិស័យ ត្រូវទទួលខុសត្រូវ ក្នុងការរៀបចំដំណើរការវាយតំលៃបរិស្ថានជាយុទ្ធសាស្រ្តនៃសំណើនោះនិងការចូលរួមជាសាធារណៈ។

**៥.** លើមាតិកាទី១ គ្រោះមហន្តរាយ និងមាតិកាទី២ ពីការប្រែប្រួលអាកាសធាតុ៖ សំណូមពរបន្ថែមការតួនាទីតាមដាន វាយតម្លៃនៃការអនុវត្ត និងគ្រប់គ្រងចំណេះដឹង ក្នុងមាត្រា ១៥២ និងកែសម្រួលពាក្យនិងឃ្លាឃ្លោង យោងតាមយោបល់លម្អិតក្នុងតារាង ដែលមានចាប់តាំងពីមាត្រា១៥២រហូតដល់មាត្រា ១៩៧។

**៦.** លើមាតិកាតំបន់ការពារធម្មជាតិ ដែលពិនិត្យចាប់ពីមាត្រា ២៩៨ដល់ មាត្រា៤៦៧។ ភាគច្រើនសំណូមពរឲ្យកែសម្រួលពាក្យពេចន៍ និងឃ្លាឃ្លោង លើកលែងតែមាត្រាមួយចំនួនដែល ត្រូវដាក់បញ្ចូលនូវភាពចាំបាច់ដូចជា៖

- មាត្រា ៣១៩៖ ក. តំបន់ស្នូលគឺត្រូវតែជាតំបន់ហាមឃាត់ដាច់ខាត
- មាត្រា ៣៣៦៖ ការប្រមូលផលដំរឈើ នៅក្នុងតំបន់អភិរក្ស ឬតំបន់ប្រើប្រាស់ដោយចីរភាពនៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវហាមឃាត់ដោយគ្មានលិខិតអនុញ្ញាតដែលមានសុពលភាព លើកលែងតែការអនុវត្តជាប្រពៃណី និងប្រើប្រាស់របស់សហគមន៍មូលដ្ឋានក្នុងតំបន់ ដូចមានចែងក្នុងមាត្រា ៣៨០។

**៧.** ការគ្រប់គ្រងរួមគ្នា៖ តាមបទបញ្ញត្តិនៃគន្ថីទី៤ មាតិកាទី៣៖ ជាទូទៅសំណូមពរឲ្យកែសម្រួលឃ្លាឃ្លោង។

៨.សំណូមពរកែសម្រួលមាត្រាមួយចំនួន និងបញ្ចូលក្នុងមាត្រាផ្សេងៗ៖

- មាត្រា ២០(៥)៖ រៀបចំយន្តការដោះស្រាយវិវាទ និងផ្តល់ដំណោះស្រាយចំពោះបណ្តឹងពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និងគ្រប់គ្រងធនធានធម្មជាតិដោយពិគ្រោះយោបល់ពេញលេញជាមួយសហគមន៍មូលដ្ឋាន ជនដែលធ្លាប់រងគ្រោះនិងក្រុមសង្គមស៊ីវិល។
- មាត្រា៣០៖ ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត អាចតម្រូវឱ្យមាន ចំពោះគម្រោងស្នើសុំ ម្ចាស់គម្រោង និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវធានាថា សហគមន៍ដែលរងផលប៉ះពាល់ ត្រូវបានផ្តល់ឱកាសដើម្បីចូលរួមពេញលេញនៅ ក្នុងការពិចារណាទៅលើជម្រើសផ្សេងៗ ដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមានូវការតាំងទីលំនៅជាថ្មី ដោយភ្ជាប់មកជាមួយនូវជម្រើសនានា រួមទាំងផែនការតាំងទីលំនៅថ្មី និងផែនទី ។ ឱកាសក្នុងការចូលរួមបែបនេះ ត្រូវតែរួចផុតពីការគម្រាមកំហែង ការបំភ័ន្ត ការកេងចំណេញ និងការបង្ខិតបង្ខំ ។
- មាត្រា៣១ ការរៀបចំផែនការការតាំងទីលំនៅថ្មី ក្នុងករណីដែលការតាំងទីលំនៅថ្មី មិនអាចជៀសវាងបាន ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវធានាថា សហគមន៍ដែលរងផលប៉ះពាល់ ត្រូវបានផ្តល់នូវឱកាស នៅក្នុងការចូលរួមរៀបចំផែនការតាំងទីលំនៅថ្មី ដោយមានការយល់ព្រមពីមតិភាគច្រើននិងពិចារណាដ៏លម្អិត សម្រាប់មតិភាគតិចដើម្បី៖
  - កាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ជាអវិជ្ជមាននៃការតាំងទីលំនៅថ្មី។
  - ធានាឱ្យបាននូវឱកាសសម្រាប់ជីវភាពរស់នៅនាពេលអនាគត និងការទទួលបានសេវាសង្គម
  - ស្មើនឹង ឬប្រសើរជាងលក្ខខណ្ឌ មុនពេលធ្វើការតាំងទីលំនៅថ្មី និងធានាឱ្យបានថា សំណងដែលសងដោយម្ចាស់គម្រោង ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់ទ្រព្យដែលបាត់បង់ និងផលប៉ះពាល់ទៅលើជីវភាពរស់នៅ គឺមានភាពយុត្តិធម៌ សមធម៌ និងអាចទទួលយកបាន ហើយក្នុងកម្រិតអប្បបរមា ស្មើនឹងតម្លៃទីផ្សារបូករួមទាំងតម្លៃប្រតិបត្តិការ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០១៧